ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

# គោលការណ៍ណែនាំអំពីការប្រើប្រាស់អំណាចក្នុងភាពអាសន្នក្នុងអំឡុងពេលនៃការរាលដាលនៃជំងឺឆ្លង

ចាប់តាំងពីការផ្ទុះឡើងនូវជំងឺឆ្លងនេះ បណ្តារដ្ឋាភិបាលក្នុងតំបន់អាស៊ីអាគ្នេយ៍ បានចាត់វិធានការមួយចំនួន រួមទាំងការប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន ដើម្បីប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូរ៉ូណា។ ឯកសារនេះមានគោលបំណងធ្វើការពន្យល់អំពីស្តង់ដាអន្តរជាតិសំខាន់ៗ ដែលពាក់ព័ន្ធនឹងស្ថានភាពអាសន្ន ព្រមទាំងចំណាត់ការដែលសមាជិកសភាអាចធ្វើបានក្នុងការការពារសិទ្ធិមនុស្ស ដោយសារសមាជិកសភាមានតួនាទីយ៉ាងសំខាន់ក្នុងការឃ្លាំមើលការអនុវត្តវិធានការទាំងនេះ ជាពិសេសការអនុលោមតាមគោលការណ៍សិទ្ធិមនុស្ស។

## តើអំណាចក្នុងភាពអាសន្នអាចត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលនៃការរាលដាលនៃជំងឺឆ្លងមួយដែរឬទេ?

រដ្ឋនានាអាចប្រកាសដាក់ប្រទេសក្នុងភាពអាសន្នបាន នៅពេលរដ្ឋទាំងនោះកំពុងប្រឈមនឹងកាលៈទេសៈពិសេស ដែលគម្រាមកំហែងដល់អាយុជីវិតរបស់ជាតិ។ ក្នុងបរិបទនៃជំងឺ COVID-19 សុខភាពសាធារណៈត្រូវបានទទួលស្គាល់ជាមូលដ្ឋានសម្រាប់រដ្ឋាភិបាលនានា ដើម្បីចាត់វិធានការសង្គ្រោះបន្ទាន់ ក្នុងគោលបំណងទប់ស្កាត់ជំងឺនេះ ព្រមទាំងផ្តល់ការថែទាំដល់អ្នកជំងឺ។ ទោះយ៉ាងណា អំណាចក្នុងភាពអាសន្នត្រូវប្រើប្រាស់ក្នុងដែនកំណត់មួយ ដែលកំណត់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចតទៅ៖

- អំណាចក្នុងភាពអាសន្នមិនត្រូវប្រើប្រាស់សម្រាប់គោលបំណងផ្សេង ក្រៅអំពីសម្រាប់ដោះស្រាយ និងបន្ធូរបន្ថយការគម្រាមកំហែងនៃជំងឺនេះនោះទេ;
- អំណាចក្នុងភាពអាសន្នត្រូវប្រើប្រាស់សម្រាប់តែពេលវេលាបណ្តោះអាសន្នប៉ុណ្ណោះ និងត្រូវត្រួតពិនិត្យជាទៀងទាត់;
- អំណាចក្នុងភាពអាសន្នត្រូវដាក់ឲ្យនៅក្រោមការត្រួតពិនិត្យរបស់ស្ថាប័ននីតិបញ្ញត្តិ និងតុលាការ។

## តើអ្វីជាដំណើរការសម្រាប់ការប្រកាស និងការបញ្ចប់ភាពអាសន្ន?

សេចក្តីប្រកាសជាផ្លូវការត្រូវតែធ្វើឡើង នៅពេលកើតមានស្ថានភាពអាសន្នជាសាធារណៈ ដែលគម្រាមកំហែងដល់អាយុជីវិតរបស់ប្រទេសជាតិ។ នីតិវិធីនេះ ដែលជាញឹកញាប់ឃើញមានចែងក្នុងរដ្ឋធម្មនុញ្ញ ត្រូវតែមានបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងច្បាប់ជាមុនសិន មុនពេលធ្វើការប្រកាស។ រដ្ឋត្រូវតែចាត់វិធានការពិសេស ដើម្បីជូនដំណឹងលម្អិតដល់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់អំពីវិធានការនានាក្នុងភាពអាសន្នដែលត្រូវបានអនុម័ត និងធានាថា ព័ត៌មានពាក់ព័ន្ធនានាត្រូវបានជូនដំណឹងជាទៀងទាត់ និងអាចទទួលបានយ៉ាងទូលំទូលាយ។ បណ្តារដ្ឋដែលបានផ្តល់សច្ចាប័នដល់កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ត្រូវជូនដំណឹងដល់ភាគីដទៃផ្សេងៗទៀតនៃកតិកាសញ្ញានេះផងដែរ។

## តើមានសិទ្ធិដែលមិនអាចត្រូវបានលុបបំបាត់ក្នុងអំឡុងពេលនៃភាពអាសន្នឬទេ?

- ក្រោមច្បាប់អន្តរជាតិ មានសិទ្ធិមនុស្សមួយចំនួនដែលមិនអាចត្រូវបានព្យួរដាច់ខាត ទោះជាស្ថិតក្នុងពេលនៃភាពអាសន្នក៏ដោយ។ សិទ្ធិមនុស្សទាំងនេះត្រូវបានស្គាល់ថាជាសិទ្ធិមិនអាចលុបបំបាត់បាន ដែលរួមមាន៖
- សិទ្ធិរស់រានមានជីវិត, សេរីភាពពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ ឬ ទង្វើឬការដាក់ទណ្ឌកម្មដ៏ថោកទាប ព្រមទាំងការពិសោធន៍វិទ្យាសាស្រ្ត ឬវេជ្ជសាស្រ្តដោយគ្មានការយល់ព្រមប្រកបដោយសេរីភាព;
- សេរីភាពពីទាសភាព ឬភាពជាអ្នកបម្រើដោយមិនស្ម័គ្រចិត្ត;
- សិទ្ធិមិនត្រូវជាប់ពន្ធនាគារដោយសារបំណុលកិច្ចសន្យា;
- សិទ្ធិមិនត្រូវបានកាត់ទោស ឬផ្តន្ទាទោសធ្ងន់ធ្ងរជាងមុន ព្រោះតែប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ;
- សិទ្ធិទទួលបានការទទួលស្គាល់ជាមនុស្សម្នាក់នៅចំពោះមុខច្បាប់;
- និងសេរីភាពនៃការគិត សតិសម្បជញ្ញៈ និងសាសនា។

## តើមានការរឹតត្បិតអ្វីខ្លះដែលត្រូវបានអនុញ្ញាតចំពោះសិទ្ធិមនុស្ស ក្នុងអំឡុងពេលនៃភាពអាសន្ន?

សិទ្ធិមនុស្សមួយចំនួន ដូចជា សេរីភាពក្នុងការធ្វើដំណើរ សេរីភាពបញ្ចេញមតិ ឬការជួបជុំដោយសន្តិវិធី អាចត្រូវបានរឹតត្បិត ដោយហេតុផលសុខភាពសាធារណៈ។ ទោះយ៉ាងណា វិធានការនានាដែលត្រូវបានអនុម័ត ដើម្បីរឹតត្បិតសិទ្ធិទាំងនេះ គឺត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម៖Measures adopted must be provided by law.

- វិធានការដែលត្រូវបានអនុម័ត ត្រូវតែមានចែងក្នុងច្បាប់;
- វិធានការដែលត្រូវបានអនុម័ត ត្រូវតែចាំបាច់សម្រាប់តែការដោះស្រាយ និងការបន្ធូរបន្ថយការគម្រាមកំហែងប៉ុណ្ណោះ។ ក្នុងករណីនេះ ដើម្បីឆ្លើយតបទៅនឹងការរាលដាលនៃជំងឺ COVID-19 ការដាក់កំហិតណាមួយ ដែលត្រូវបានដាក់ចេញសម្រាប់គោលបំណងផ្សេងពីនេះ អាចមានន័យស្មើនឹងការរំលោភអំណាច;
- វិធានការដែលត្រូវបានអនុម័ត ត្រូវមានលក្ខណៈសមស្រប (សមស្របក្នុងការបំពេញតាមតម្រូវការចាំបាច់នៃសុខភាពសាធារណៈ) និងមានផលប៉ះពាល់តិចបំផុតតាមដែលអាចធ្វើបាន;
- វិធានការដែលត្រូវបានអនុម័ត មិនត្រូវមានការរើសអើង និងប្រើប្រាស់ក្នុងគោលបំណងសំដៅដល់បុគ្គល ឬក្រុមណាមួយជាក់លាក់ រួមទាំងជនភាពតិចនោះទេ។ឧទាហរណ៍

នៅពេលដាក់ទោសចំពោះការរំលោភបំពានលើវិធានការក្នុងភាពអាសន្ន ចំណាត់ការចុងក្រោយរបស់រដ្ឋគួរតែជាការដកហូតត្រឹមតែសេរីភាពរបស់ពួកគេប៉ុណ្ណោះ ហើយទោសត្រូវសមាមាត្រនឹងភាពធ្ងន់ធ្ងរនៃបទល្មើស។ ការដាក់ទោសមិនត្រូវធ្វើឡើងតាមទំនើងចិត្ត ឬក្នុងលក្ខណៈរើសអើងនោះទេ។

## តើតុលាការមានតួនាទីអ្វីខ្លះក្នុងអំឡុងពេលនៃភាពអាសន្ន?

សូម្បីតែនៅក្នុងពេលនៃភាពអាសន្ន ទាំងការប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន និងវិធានការនានាដែលត្រូវបានអនុម័តនៅក្រោមស្ថានភាពអាសន្ននេះ គឺត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ នេះគឺជាការការពារដ៏សំខាន់ដើម្បីធានាថា អំណាចពិសេសនេះកំពុងត្រូវបានប្រើប្រាស់តែសម្រាប់ឆ្លើយតបចំពោះការគម្រាមកំហែងដូចបានបញ្ជាក់រួចហើយ។ តុលាការក៏ត្រូវតែបន្តវិនិច្ឆ័យលើបណ្តឹងអំពីការរំលោភបំពានសិទ្ធិដែលមិនអាចរឹតត្បិតក្នុងពេលនៃភាពអាសន្ន។ លើសពីនេះទៅទៀត សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ដូចជា ការសន្មត់ថាគ្មានទោស ការណ៍ដែលមានតែតុលាការប៉ុណ្ណោះដែលអាចដាក់ទោសជនល្មើសនៃបទល្មើសព្រហ្មទណ្ឌ ការហាមមិនឲ្យមានការឃុំខ្លួននៅទីកន្លែងដែលមិនអាចទាក់ទងបាន ឬក្នុងរយៈពេលមិនជាក់លាក់ណាមួយ។ល។) ត្រូវយកមកប្រើក្នុងពេលនៃភាពអាសន្ន។

## តើប៉ូលិសមានអំណាចអ្វីខ្លះក្នុងអំឡុងពេលនៃភាពអាសន្ន?

ប៉ូលិស និងមន្រ្តីអនុវត្តច្បាប់ទាំងអស់ ត្រូវប្រើប្រាស់កម្លាំង តែក្នុងពេលដែលចាំបាច់បំផុត និងពេលដែលវិធានការមានផលប៉ះពាល់តិចតួចមិនមានប្រសិទ្ធភាពប៉ុណ្ណោះ។ សូម្បីតែក្នុងពេលនៃភាពអាសន្ន ស្តង់ដា និងវិធានច្បាប់អន្តរជាតិ (ដូចជា ក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តច្បាប់ គោលការណ៍មូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងកាំភ្លើងដោយមន្ត្រីអនុវត្តច្បាប់ ព្រមទាំងគោលការណ៍ណែនាំសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ស្តីពីការប្រើប្រាស់អាវុធដែលមិនសូវមានគ្រោះថ្នាក់ដល់អាយុជីវិតដោយមន្ត្រីអនុវត្តច្បាប់) ត្រូវតែអនុលោមតាម។ លើសពីនេះទៅទៀត ជាទូទៅ យោធាមិនត្រូវអនុវត្តមុខនាទីរបស់ប៉ូលិសនោះទេ ហើយរាល់ការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្សដោយមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីយោធា ត្រូវតែធ្វើការស៊ើបអង្កេតដោយឯករាជ្យ និងនាំខ្លួនអ្នកដែលត្រូវបានរកឃើញមានកំហុសយកទៅដាក់ទោស។

## តើសមាជិកសភាដើរតួនាទីអ្វីខ្លះក្នុងអំឡុងពេលនៃការដាក់ប្រទេសក្នុងភាពអាសន្ន?

ក្នុងនាមជាតំណាងជាប់ឆ្នោតដោយផ្ទាល់ សមាជិកសភាដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងកូរ៉ូណា និងធានាថាវិធានការទាំងនេះស្របជាមួយគោលការណ៍សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ។ ក្នុងន័យនេះ ពិតជាមានភាពចាំបាច់ដែលសភាត្រូវដំណើរការក្នុងអំឡុងពេលនៃភាពអាសន្ន និងអនុញ្ញាតឲ្យសមាជិកសភាអនុវត្តអាណត្តិរបស់ខ្លួនយ៉ាងពេញលេញ។ ជាពិសេស សមាជិកសភាត្រូវមានលទ្ធភាពអាចផ្តល់ការត្រួតពិនិត្យតាមកាលកំណត់ និងទៀងទាត់ លើភាពចាំបាច់នៃការប្រើប្រាស់អំណាចក្នុងភាពអាសន្ន ដើម្បីការពារសុខភាពសាធារណៈ ព្រមទាំងការប្រើប្រាស់វិធានការ និងច្បាប់ ដែលត្រូវបានអនុម័តក្រោមស្ថានភាពអាសន្ននោះ។ ជាការណ៍សំខាន់ណាស់ សមាជិកសភាក៏ត្រូវមានតួនាទីក្នុងការធានាថា រដ្ឋយកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្ស នៅពេលឆ្លើយតបនឹងជំងឺ COVID-19។ តួនាទីនេះរួមមាន ការជម្រុញឲ្យរដ្ឋាភិបាលពិចារណាលើផលប៉ះពាល់នៃវិធានការបែបនោះទៅលើអ្នកដែលប្រឈមនឹងគ្រោះថ្នាក់ រួមមានស្ត្រី ជនជាតិភាគតិច ឬក្រុមសាសនាភាគតិច ជនជាតិដើមភាគតិច ជនចំណាកស្រុក និងជនភៀសខ្លួន មនុស្សចាស់ ជនពិការ និងអ្នកស្រលាញ់ភេទដូចគ្នា។

**សម្រាប់ព័ត៌មានបន្ថែម សូមចូលពិនិត្យមើល៖**

- UN Office of the High Commission for Human Rights, Emergency Powers and Covid19: Guidance
- The Siracusa Principles on the limitation and derogation provisions in the International Covenant on Civil and Political Rights
- UN Human Rights Committee, General Comment No. 29, Derogations during a State of Emergency.
- APHR, MPs warn against authoritarian turn of COVID-19 responses
- APHR, Essential parliamentary work must resume at the earliest, regional lawmakers say

ASEAN PARLIAMENTARIANS FOR HUMAN RIGHTS
www.aseanmp.org | Facebook / Twitter / Instagram: @ASEANMP